


អ្នកនិពន្ធ៖ ជា ប៊ុនណា[1], កង ក្រឹស្នា[1], Jessie Vipham[2], Lisa Tokach[3], Mike Tokach[2]

[1] មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ភ្នំពេញ កម្ពុជា

[2] Department of Animal Sciences and Industry, Kansas State University, Manhattan, Kansas, USA

[3] Abilene Animal Hospital, Abilene, Kansas, USA


## កម្មវិធីផ្សព្វផ្សាយកសិកម្មស៊ីសេន

**CE SAIN Agricultural Extension Program**

កម្មវិធីនេះបំពេញមុខងារជាវេទិកាមួយដែលជួយសម្របសម្រួលដល់កសិករ ស្ថាប័នអប់រំ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការទទួលព័ត៌មានចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ទាក់ទងនឹងបច្ចេកទេសកសិកម្មដើម្បីធានាដល់ការផ្សព្វផ្សាយការអនុវត្តការគ្រប់គ្រងកសិកម្មល្អៗ។ កម្មវិធីនេះជួយធ្វើឲ្យប្រសើរឡើងនូវចំណេះដឹង និងការអនុវត្តបច្ចេកទេសកសិកម្មដោយផ្អែកលើនវានុវត្តន៍ និងការស្រាវជ្រាវវិទ្យាសាស្ត្រជាមូលដ្ឋាន។

អ៊ីម៉ែល៖ cesain@rua.edu.kh | គេហទំព័រ៖ www.cesain.org

### សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖


លោក ជា ប៊ុនណា

លេខទូរស័ព្ទ៖ (៨៥៥)៦៩ ៩២១ ៦៦២ | សារអេឡិចត្រូនិច៖ bunna_chea@rua.edu.kh



FEED THE FUTURE

The U.S. Government's Global Hunger & Food Security Initiative




# ជំងឺជ្រូក និងវិធានការការពារ (ភាគ១)

# PIG DISEASES AND PREVENTION (PART I)


USAID FROM THE AMERICAN PEOPLE

KANSAS STATE UNIVERSITY

ILRI INTERNATIONAL LIVESTOCK RESEARCH INSTITUTE

CGIAR

UF IFAS UNIVERSITY of FLORIDA

# ជំងឺ និងវិធានការការពារក្នុងការចិញ្ចឹមជ្រូក

## និយមន័យ៖ ជំងឺបង្កដោយវីរុស បាក់តេរី និងបរាសិត

**ជំងឺបង្កដោយវីរុស៖** សូមចងចាំថាវីរុសដែលបង្កជំងឺចូលទៅរស់នៅក្នុងកោសិការបស់សត្វដែលអង់ទីប្យូទិចមិនអាចសម្លាប់វាបានទេ។ វិធីសាស្ត្រដែលល្អបំផុតសម្រាប់ការកាត់បន្ថយជំងឺបង្កដោយវីរុសគឺត្រូវចាក់វ៉ាក់សាំងសត្វ និងអនុវត្តប្រព័ន្ធជីវៈសុវត្ថិភាពឲ្យបានត្រឹមត្រូវ។

**ជំងឺបង្កដោយបាក់តេរី៖** យើងអាចប្រើប្រាស់អង់ទីប្យូទិចសម្រាប់ព្យាបាលបាន ប៉ុន្តែយើងគួរអនុវត្តតាមលំនាំជីវសុវត្ថិភាព និងចាក់វ៉ាក់សាំងសត្វឲ្យបានត្រឹមត្រូវ។ ជំងឺដែលបង្កដោយបាក់តេរីមួយចំនួនអាចប្រើប្រាស់វ៉ាក់សាំងការពារបាន។

**ជំងឺបង្កដោយបរាសិត៖** អាចធ្វើឲ្យមានការខាតបង់ក្នុងការចិញ្ចឹមដោយធ្វើឲ្យជ្រូកមានការលូតលាស់យឺត និងងាប់បើសិនជាមិនមានការព្យាបាល។

## ជំងឺជ្រូកដែលតែងតែជួបប្រទះនៅកម្ពុជា

### ជំងឺដែលបង្កដោយវីរុស



- ជំងឺអុតក្តាមជ្រូក (FMD)
- ជំងឺប៉េស្តជ្រូក (CSF)
- ជំងឺឆ្កួតជ្រូកក្លែងក្លាយ ឬអូហ្សេស្គី (Aujesky's Disease)
- ជំងឺក្រិនជ្រូក (PCV)
- ជំងឺផ្តាសាយជ្រូក (SIV)
- ជំងឺត្រចៀកខៀវជ្រូក (PRRS)
- ជំងឺរាកកូនជ្រូក (PED)
- ជំងឺរលាកក្រពះពោះវៀនជ្រូក (TGE)

### ជំងឺដែលបង្កដោយបរាសិត





- ព្រូនក្នុងពោះវៀន
- ចៃ និងអង្កែរ
- កុកស៊ីដ្យូស៊ីស

### ជំងឺដែលបង្កដោយបាក់តេរី



- ជំងឺសាល់ម៉ូណែឡា
- ជំងឺសារទឹក
- ជំងឺម៉ាយកូប្លាស្មា
- ជំងឺរាកអ៊ីកូលី
- ជំងឺស្ត្រិបតូកូគូស
- ជំងឺកញ្ច្រិល
- ជំងឺរលាកចុងពោះវៀនតូច

## តើវីរុស បាក់តេរី និងបរាសិតអាចចម្លងជំងឺទៅជ្រូកតាមរយៈណាខ្លះ?

- លាមក
- ទឹកមាត់
- ឈាម
- សាច់ជ្រូក
- ទឹកនោម
- ស្លែមជ្រូក













## តើមានវិធីសាស្ត្រអ្វីខ្លះដើម្បីសម្លាប់មេរោគ?

- **ទឹក៖** លាងសម្អាតជ្រូក និងសម្ភារប្រើជាមួយជ្រូក
- **បោសសម្អាត៖** បោសលាមកពីខ្លួនជ្រូក និងទ្រុងជ្រូក
- **កម្តៅ៖** សម្ងួតសម្ភារប្រើជាមួយជ្រូក
- **ថ្នាំសម្លាប់មេរោគ**









## តើកត្តាអ្វីខ្លះដែលអាចចម្លងជំងឺទៅជ្រូកអ្នក?

ក. ប្រភពជ្រូកផ្សេងៗអាចជាកត្តាចម្លងជំងឺដល់ជ្រូកអ្នក

ខ. ការផ្តល់កាកសំណល់ភោជនីដ្ឋាន ឬកាកសំណល់ផ្ទះបាយអាចចម្លងជំងឺដល់ជ្រូកអ្នក

គ. អ្នកដទៃដែលមកមើលជ្រូកអ្នកអាចចម្លងជំងឺមកជ្រូកអ្នក

ឃ. ការប្រើសម្ភារផ្សេងៗលើជ្រូករួមគ្នាអាចចម្លងជំងឺដល់ជ្រូកអ្នក

ង. ការចិញ្ចឹមសត្វផ្សេងៗលាយឡំជាមួយជ្រូកអាចចម្លងជំងឺដល់ជ្រូកអ្នក

